# ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០១-៥-២០០៣ -ព្រះរាជក្រឹត្យនស/រកត/០៥០៣/១៦៣ ស្តីពីការតែងតាំង ឯកឧត្តម **ចឹន ហេងប៉ូល** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា ១៨១០

០១-៥-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៦៤ ស្តីពីការតែងតាំង ឯកឧត្តម **ចឹន សុវណ្ណា** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា ១៨១១

០៧-៥-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៦៧ ស្តីពីការតែងតាំង ឯកឧត្តម **ជា សុន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋមន្ត្រី ១៨១២

០៩-៥-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៦៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ហុង ទិនចុង** ( HUNG WEN CHUNG) សញ្ជាតិដើមចិន កើតនៅកោះតៃវ៉ាន់ប្រទេសចិន ១៨១៣

០៩-៥-២០០៣ - ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៦៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោកស្រី **ហេឡិន ចាវីស** ( HELEN JARVIS) សញ្ជាតិដើមអូស្ត្រាលី កើតនៅទីក្រុង ស៊ីដនី ប្រទេសអូស្ត្រាលី ១៨១៤

០៩-៥-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៧០ស្តីពីការផ្ទេរក្របខ័ណ្ឌ លោក **អ៊ឹង សេរីវិសុទ្ធ** អនុមន្ត្រី ថ្នាក់លេខ ១២ ពីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកជា អនុមន្ត្រីថ្នាក់ទី ១២ ក្របខ័ណ្ឌមន្ត្រីការទូត ជាន់ខ្ពស់ ក្រ សួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ១៨១៥


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


អនុក្រឹត្យលេខ ៣២ អនក្រ.បក (**គ្មាន**)

១២-៥-២០០៣ - អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៨១៧

១២-៥-២០០៣ - អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ១៨១៩

១៣-៥-២០០៣ - អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការ ត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ១៨២១

១៤-៥-២០០៣ - អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការ បណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ១៨២៦

18

# ខ


| | | |
|---|---|---|
| ១៤-៥-២០០៣ | - អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មការ សំរាប់តាមដាន ការអនុវត្ត កិច្ចសន្យាសម្បទានព្រលានយន្តហោះភ្នំពេញ និង សៀមរាប | ១៨២៩ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤០៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣២ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤០៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៣ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤០៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៤ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤០៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៥ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤១០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៧ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤១១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៣៨ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤១២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៤០ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៣អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៤១ |
| ០៩-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ១៨៤២ |
| ១៣-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៥ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ១៨៤៣ |
| ១៣-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៨៤៤ |
| ១៤-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៧ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ១៨៤៦ |
| ១៤-៥-២០០៣ | - អនុក្រឹត្យលេខ ៤១៨ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ១៨៤៧ |


## ២. សេចក្ដីសំរេច


| | | |
|---|---|---|
| ១៣-៥-២០០៣ | -សេចក្ដីសំរេចលេខ ៣៨ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិភាក្សា លើឯកសារទស្សនទានកម្ពុជា-ថៃ | ១៨៤៨ |
| ១៤-៥-២០០៣ | -សេចក្ដីសំរេចលេខ ៣៩ សសរ ស្ដីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ាន (AEM) លើកទី ៣៥ និងកិច្ចប្រជុំពាក់ព័ន្ធ | ១៨៥០ |
| ១៤-៥-២០០៣ | -សេចក្ដីសំរេចលេខ ៤០ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយ រាល់បាតុភាព ដែលទាក់ទងដល់អតីតបុរិកម្មករអគ្គិសនីក្បាលថ្នល់ ស្ថិតក្នុងរាជធានីភ្នំពេញ | ១៨៥៣ |

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៦៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ:២៦០ រ.ស ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៣

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ចិន ហេងប៊ុល** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ទទួលបន្ទុកផ្នែកច្បាប់ និងសិទ្ធិមនុស្សមានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៣

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

ពរល.០៣.០៥.១៧៤ លេខ : ៧៤៦ ច.ល **ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ប្រាក់ សុខុន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៦៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខៈ២៦១ រ.ស ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៣

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ប៊ិន សុវណ្ណា** ជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ទទួលបន្ទុកទំនាក់ទំនងជាមួយប្រជារាស្ត្រ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៣

**ឡកព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

៣រល.០៣.០៥.១៧៥ លេខ :១៥៥ ច.ល **ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ឡាក់ សុខុន

# ព្រះរាជក្រឹត្យ

នស / រកត / ០៥០៣/១៦៧

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តម **ជា សុន** ជាទីប្រឹក្សាផ្ទាល់របស់ **សម្តេចប្រធានព្រឹទ្ធសភា** មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ ២០០៣
ឡូវព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ : ៦៤១ ច.ល

៣៧ល.០៣.០៥.១៧ សេចក្តីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០០៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
[illegible] សុខុន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៦៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហុង ទីនចុង** (HUNG WEN CHUNG) សញ្ជាតិដើមចិន កើតថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៥២ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៧៤-០៣-០៥-១៧៥

លេខ : ១៤៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៦៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ លោកស្រី **ហេឡិន ចាវីស** (HELEN JARVIS) សញ្ជាតិដើមអូស្ត្រាលី កើតថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៤៦ នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០០៣

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ចករ**

៣៧ល.០៣.០៥.១៨០ លេខ : ១៤៧ ច.ល

**ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ថ្លាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៧០

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

មាត្រា ១.–

ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក **អ៊ឹង សេរីវិសុទ្ធ** អនុមន្ត្រី ថ្នាក់លេខ ១២ ពីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកជាអនុមន្ត្រី ថ្នាក់លេខ ១២ ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២.–

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.–

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.–

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

៣កស-០៣.០៥.១៨១ លេខ :១៤៤ ច.ល **ជា ស៊ីម**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.៥០០ លានរៀល ( បួនពាន់ប្រាំរយលានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១. ចុះថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សំរេច

**មាត្រា១:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ជាប្រធាន |
| ២-ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣-ឯកឧត្តម **ចាយ សាំងយុន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៤-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម **ហ៊ុល កន្ទួល ទរ៉ា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៦-ឯកឧត្តម **ចំនួ តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ | ជាសមាជិក |

| | | |
|---|---|---|
| ៧-ឯកឧត្តម **អ៊ូ ឱហាត** | រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| ៨-លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៩-ឯកឧត្តម **ឆាន់ សារ៉ាឆាន់** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| ១០-ឯកឧត្តម **ទៅ ពិន** | រដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម | ជាសមាជិក |
| ១១-ឯកឧត្តម **នឹម ថូត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ជាសមាជិក |
| ១២-ឯកឧត្តម **ឌុច ទននិត្យ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម | ជាអគ្គលេខាធិការ |

**មាត្រា ២ :** គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានបេសកកម្មអនុវត្តនូវសិទ្ធិអំណាចក្នុងសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....៣៥.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទំងន់ក៏រិតកំណត់អតិបរមា

\~\~\~\~\~ * \~\~\~\~\~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការកំណត់ទំងន់អតិបរមា នៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែលបើកបរលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

## សំរេច

**មាត្រា ១.-**

បង្កើតគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់ក៏រិតកំណត់អតិបរមាគ្រប់ប្រភេទ ដែលបើកបរលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកក្នុងការថែរក្សាគុណភាពផ្លូវជាតិ និងស្ពានទាំងឡាយឱ្យស្ថិតស្ថេរយូរអង្វែង ។

4

**មាត្រា ២.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការងាររដ្ឋបាល មួយរូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៥- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៦- អភិបាលរងខេត្ត ក្រុងមួយរូប | សមាជិក |
| ៧- ប្រធានគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ | សមាជិកអចិន្ត្រៃយ៍ |

ប្រធានគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត និងអភិបាលខេត្ត ក្រុង ចូលរួមប្រជុំតាមការចាំបាច់ ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៣.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានភារកិច្ច :

- រៀបចំ និងដាក់ចេញនូវវិធានការឱ្យអនុវត្តការត្រួតពិនិត្យ និងការទប់ស្កាត់រាល់ការដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមាលើផ្លូវជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា
- សំរបសំរួល តាមដាន ត្រួតពិនិត្យការអនុវត្តការងាររបស់គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍
- រាយការណ៍ជូនរាជរដ្ឋាភិបាល អំពីសកម្មភាពត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ជាសេនាធិការទទួលបន្ទុកការងារសំរបសំរួល តាមដានជាប្រចាំការអនុវត្តនីការងារបង្ក្រាបរាល់ការដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមាលើផ្លូវជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- តំណាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- តំណាងអគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៦- តំណាងអគ្គាធិការដ្ឋាននៃក្រសួង ស.ជ.ក សមាជិក

៧- តំណាងអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួង ស.ជ.ក សមាជិក

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ត្រូវតែងតាំងដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ។

**មាត្រា ៥.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ មានភារកិច្ច :

- បង្កើត និងរៀបចំសមាសភាពក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- សំរបសំរួល ជំរុញត្រួតពិនិត្យសកម្មភាពរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំកម្មវិធីត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំធ្វើសេចក្តីកំណត់តួនាទី និងភារកិច្ចរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំ និងចាត់ចែងធ្វើតារាងបែងចែកដាក់ និងផ្លាស់ប្តូរទីតាំងត្រួតពិនិត្យ សំរាប់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- រៀបចំបេសកកម្ម ព្រមទាំងតាមដានរាល់សកម្មភាពរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធ ជាមួយអាជ្ញាធរដែនដី ខេត្ត ក្រុង
- អនុវត្តការដាក់ពិន័យតាមកំហុសជាក់ស្តែង ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ប្រគល់ជូន ។

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ អាចប្រើប្រាស់មន្ត្រីជំនាញ តាមសមត្ថកិច្ចរៀងៗខ្លួនតាមពេលវេលា និងទំហំការងារចាំបាច់ ។

**មាត្រា ៦.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍មានតួនាទីគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការដាក់ពិន័យ ដើម្បីបង់ចូលថវិការដ្ឋ ។

**មាត្រា ៧.-**

គណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ ត្រូវកំណត់បទបញ្ជាផ្ទៃក្នុង បែងចែកភារកិច្ច និងរៀបចំកម្មវិធីចុះបេសកកម្ម ។ ក្រោយពេលចុះបេសកកម្ម ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល និងវិធានការដោះស្រាយរបស់ក្រុមត្រួតពិនិត្យ ជូនគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ដើម្បីពិនិត្យ និងលើកគោលការណ៍ វិធានការ សំរាប់ណែនាំអនុវត្តបន្ត ។

**មាត្រា ៨.-**

ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមានីមួយៗ មានសមាសភាពដូចតទៅ :

១- តំណាងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ប្រធាន

២- តំណាងអាជ្ញាធរដែនដីខេត្ត ក្រុង អនុប្រធាន

៣- តំណាងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង សមាជិក

៤- តំណាងស្នងការដ្ឋាននគរបាលខេត្ត ក្រុង សមាជិក

៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦- មន្ត្រីជំនាញដែលមានចំនួនទៅតាមការចាំបាច់ជាក់ស្តែងរបស់ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា មានជាអាទិ៍ : ជំនាញជញ្ជីង នគរបាល កងរាជអាវុធហត្ថ សមាជិក

**មាត្រា ៩.-**

ក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមានីមួយៗ មានភារកិច្ច :

- ត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- ផាកពិន័យតាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា
- អនុវត្តតាមបទបញ្ជា ហើយរាយការណ៍ជូនគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ជាប្រចាំ
- អនុវត្តការផាកពិន័យតាមកំហុសជាក់ស្តែង ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ប្រគល់ជូន ។

**មាត្រា ១០.-**

ក្រោយពេលដែលអនុក្រឹត្យនេះចូលជាធរមាន ដើម្បីបន្តនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា គណៈកម្មការចំរុះត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងអនុគណៈកម្មការអចិន្ត្រៃយ៍ត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ដែលបង្កើតដោយប្រកាសលេខ ០៤៨ ប្រក.ស.ក.បធ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០១ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបន្តសកម្មភាពត្រួតពិនិត្យរបស់ខ្លួន នៅលើបណ្តាញផ្លូវជាតិទាំងអស់ រួមទាំងផ្លូវជាតិលេខ៥ និងផ្លូវពីប៉ោយប៉ែត ទៅសៀមរាបផងដែរ ដោយត្រូវក្លាយជាគណៈកម្មការសំរបសំរួលអចិន្ត្រៃយ៍ និងក្រុមត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទំងន់កំរិតកំណត់អតិបរមា ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានឃើញ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ**

**និងដឹកជញ្ជូន**

**ឃី តាំងលឹម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច √
- កាលប្បវត្តិ ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/ ០៦០២ /១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការ បង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## ស ម្រេ ច

### មាត្រា ១.-

បង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកពិនិត្យ និងអនុម័តពាក្យច្បាប់ ហៅកាត់ថា "គណៈកម្មការបណ្ឌិតសភា" ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| - ឯកឧត្តម | សំ សុខផល | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ប្រធាន |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ស៊ិន សំណាង | ប្រធានរាជបណ្ឌិតសភាកម្ពុជា | អនុប្រធាន |
| -ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ឆយ យីហ៊ាង | សមាជិករាជបណ្ឌិតសភាកម្ពុជា ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិតសភាកម្ពុជា | |

| | | | |
|---|---|---|---|
| -លោកសាស្ត្រាចារ្យ បណ្ឌិត | ច័ន្ទ សំណព្វ | ប្រធាននាយកដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| - លោកសាស្ត្រាចារ្យ | សឹង ផុស | អនុប្រធាននាយកដ្ឋានអក្សរសាស្ត្រខ្មែរ នៃវិទ្យាស្ថានភាសាបរទេស តំណាងវិទ្យាស្ថានភាសា-បរទេសកម្ពុជា | សមាជិក |
| - លោក | ប៊ុន ហុន | មេធាវី តំណាងគណៈមេធាវីកម្ពុជា | សមាជិក |
| - តំណាងក្រសួងពាក់ព័ន្ធ | | | សមាជិក |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ហេង វង្សប៊ុនឆាត | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ទីប្រឹក្សា |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | សុខ ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ទីប្រឹក្សា |

ទីប្រឹក្សារបស់គណៈកម្មការបណ្ឌិតសភា ពុំមែនជាសមាជិករបស់គណៈកម្មការនេះទេ។ ទីប្រឹក្សាត្រូវបានអញ្ជើញឱ្យចូលរួមជាមួយគណៈកម្មការបណ្ឌិតសភាគ្រប់ពេល។ លោកអាចជូនមតិយោបល់បាន ប៉ុន្តែលោកពុំចូលរួមបោះឆ្នោតសម្តែងមតិក្នុងគណៈកម្មការឡើយ ។

ក្រសួងពាក់ព័ន្ធត្រូវចាត់បញ្ជូនតំណាង ទៅតាមសេចក្តីស្នើសុំរបស់គណៈកម្មការបណ្ឌិតសភា ។

**មាត្រា ២.-**

គណៈកម្មការបណ្ឌិតសភា មានភារកិច្ចពិនិត្យ និងអនុម័តពាក្យច្បាប់ដែលកំពុងប្រើប្រាស់ ពាក្យច្បាប់ថ្មី និងពាក្យច្បាប់ដែលបកប្រែពីភាសាបរទេស ។ នីតិវិធី នៃការពិនិត្យ និងអនុម័តពាក្យរបស់គណៈកម្មការបណ្ឌិតសភា ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងមួយ ដែលគណៈកម្មការអនុម័តខ្លួនឯង។

ពាក្យទាំងឡាយដែលគណៈកម្មការបណ្ឌិតសភាអនុម័តរួចហើយ ត្រូវចងក្រងជាសទ្ទានុក្រម និងត្រូវបញ្ជូនទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការប្រកាសឱ្យប្រើនៅទូទាំងប្រទេស ។

**មាត្រា ៣.-**

គណៈកម្មការបណ្ឌិតសភា មានលេខាធិការដ្ឋានមួយជាជំនួយការ ។

លេខាធិការដ្ឋានជាអង្គភាពបច្ចេកទេស ដែលជួយគណៈកម្មការក្នុងការងារព្រាងពាក្យ ការងាររដ្ឋបាល ការងារភស្តុភារ និងហិរញ្ញកិច្ច ព្រមទាំងការងារផ្សេងៗទៀត ពាក់ព័ន្ធនឹងគណៈកម្មការ ។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤.-**

គណៈកម្មការបណ្ឌិតសភា ស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

គណៈកម្មការបណ្ឌិតសភា អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន និងពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ព្រមទាំងមន្ត្រីដែលពាក់ព័ន្ធដទៃទៀត ត្រូវអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**"ដើម្បីសុំហត្ថលេខា"**

**សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ឌិត មុន្ទី** **សុខ អាន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នរដ្ឋ

-ដូចមាត្រា ៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការសំរាប់តាមដានការអនុវត្តកិច្ចសន្យាសម្បទានព្រលានយន្តហោះភ្នំពេញ និងសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មការមួយ ដើម្បីតាមដានការអនុវត្តកិច្ចសន្យាសម្បទានព្រលានយន្តហោះភ្នំពេញ និងសៀមរាប ក្នុងគោលបំណងធានាប្រណិតភាពនៃការអនុវត្តនេះ ទាំងលើវិស័យសង្គម វិស័យបច្ចេកទេស និងវិស័យហិរញ្ញវត្ថុ ។

**មាត្រា ២.-**

សមាសភាពនៃគណៈកម្មការនេះ រួមមាន :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម | **ញ៉ាណោ ឡេង** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣- ឯកឧត្តម | **ធា សុផ្លា** | តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ជាសមាជិក |
| ៤- ឯកឧត្តម | **សុខ ចិន្តា** | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |

ប្រធានអាចជ្រើសរើសអ្នកច្បាប់មួយរូបដើម្បីធ្វើកំណត់ហេតុនៅពេលប្រជុំ ។

**មាត្រា ៣.-**

គណៈកម្មការ ប្រជុំទៀងរាល់បីខែម្តង តាមការកោះអញ្ជើញរបស់ប្រធាន ។ កិច្ចប្រជុំលើកទី១ ត្រូវធ្វើឡើង ៦០ ថ្ងៃ ក្រោយពីថ្ងៃអនុក្រឹត្យនេះ ចូលជាធរមាន ។

ដើម្បីបំពេញបេសកម្មរបស់ខ្លួន គណៈកម្មការពិនិត្យរបាយការណ៍ដែលក្រុមហ៊ុនសម្បទានព្រលានយន្តហោះ ធ្វើជូនទៀងទាត់ប្រចាំត្រីមាស ហើយដែលមានបញ្ជាក់យ៉ាងល្អិតល្អន់ផងដែរអំពីស្ថានភាពនៃប្រតិបត្តិការសម្បទាននោះ ព្រមស្ថិតិទាំងឡាយទាក់ទងនឹងប្រតិបត្តិការនេះ ។ របាយការណ៍របស់ក្រុមហ៊ុនមានចុះផងដែរនូវចំណុចទាំងឡាយដែលជាភាពរអាក់រអួលនៃប្រតិបត្តិការនោះ ។

គណៈកម្មការព្យាយាមដោះស្រាយបញ្ហាទាំងឡាយ ជាមួយនឹងក្រសួង និងបណ្តាក្រសួងពាក់ព័ន្ធផ្សេងទៀត ហើយធ្វើរបាយការណ៍សរុបជូនរាជរដ្ឋាភិបាល ។

គណៈកម្មការអាចតម្រូវឱ្យក្រុមហ៊ុនសម្បទានកែលំអនូវសកម្មភាពប្រតិបត្តិការរបស់ខ្លួន បើគណៈកម្មការយល់ឃើញថា មានការខ្វះខាត ។

**មាត្រា ៥.-**

ក្នុងករណី ដែលការពិភាក្សា រវាងគណៈកម្មការនិងក្រុមហ៊ុនសម្បទាន បង្ហាញថា មានចំណុចមួយឬមួយចំនួននៃកិច្ចសន្យាដើម និងកិច្ចសន្យាបន្ថែមបន្តបន្ទាប់មកទៀត តម្រូវឱ្យមានការកែលំអ ឬការបន្ថែមបន្ថយ គណៈកម្មការត្រូវរៀបចំកិច្ចសន្យាបន្ថែមមួយទៀត នឹងដាក់ជូនរាជរដ្ឋាភិបាល និងក្រុមហ៊ុនសម្បទាន ចុះហត្ថលេខា មិនឱ្យហួសថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៤ ។

**មាត្រា ៦.-**

គណៈកម្មការ មានសិទ្ធិទាមទារគ្រប់ឯកសារនិងពត៌មានទាំងឡាយពីក្រុមហ៊ុនសម្បទាន ក៏ដូចជាក្រសួងនានាដើម្បីសម្រេចបេសកម្មរបស់ខ្លួន ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៤០៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ ខ្នង ជូនសាលាបឋមសិក្សា សែនសុខ អន្លង់ក្ងាន ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ដូចមាននាមខាងក្រោម÷

១-លោក IKEMA TETSURO ប្រធានសមាគម OKINAWA នៅប្រទេសជប៉ុន បរិច្ចាគថវិកា ២០.០០០ USD

២-លោក **សោម មនោរក្ស** បរិច្ចាគថវិកា ១៣.៧០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៤០៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងវិស័យអប់រំ នៅស្រុកពារាំង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ÷

